**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៣ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងតាក់តែងគោលនយោបាយលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩៨៩ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលដំឡើងឋានៈ និងតែងតាំងសមាសភាពថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- តាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## សម្រេច

**ប្រការ១ :** បង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងតាក់តែងគោលនយោបាយលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តមវេជ្ជបណ្ឌិត | **ទា ផលា** | អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | ប្រធាន |
| ២. លោកជំទាវ | **មាសសាឯម ដានី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣. លោកជំទាវ | **កែវ ចរិយា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. ឯកឧត្តមសាស្ត្រាចារ្យ | **ស៊ា ហួច** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៥. ឯកឧត្តមវេជ្ជបណ្ឌិត | **ហោ ប៊ុនឡេង** | អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | អនុប្រធានប្រចាំការ |
| ៦. ឯកឧត្តម | **ហោ សារុន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៧. ឯកឧត្តម | **ហ៊ុយ ហានសុខ** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៨. ឯកឧត្តម | **ខាយ ឃុនហេង** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៩. លោកជំទាវ | **សាន្ត អរុណា** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិកា |
| ១០. ឯកឧត្តម | **ប៉ាន ប៊ុនធឿន** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១១. លោកជំទាវ | **ឆៃ ច័ន្ទរិទ្ធី សូលីដា** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិកា |
| ១២. លោកជំទាវ | **ខៀវ បូរី** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិកា |
| ១៣. ឯកឧត្តមនាយឧត្តមសេនីយ៍ | **សម តារា** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១៤. លោកជំទាវ | **សឿ សុជាតា** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិកា |
| ១៥. ឯកឧត្តមបណ្ឌិត | **ចន ណារិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម | សមាជិក |
| ១៦. លោកជំទាវ | **ខៀវ សុផានី** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិកា |
| ១៧. ឯកឧត្តម | **ឆៀង វណ្ណាដារ៉ុង** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៨. ឯកឧត្តមវេជ្ជបណ្ឌិត | **រស់ សីលវ៉ាត់** | អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | សមាជិក |
| ១៩. ឯកឧត្តមបណ្ឌិត | **ឈឹម ឃិនដារ៉េត** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | លេខាធិការ |
| ២០. លោកស្រី | **Patricia Ongpin** | នាយកអង្គការ UNAIDS ប្រចាំប្រទេសកម្ពុជា | ទីប្រឹក្សា។ |

**ប្រការ២ :** ក្រុមការងារបច្ចេកទេសអន្តរក្រសួងនេះ មានមុខងារ និងភារកិច្ច ដូចខាងក្រោម៖

- សិក្សា និងរៀបចំគោលនយោបាយលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨
- សិក្សា និងវិភាគឱ្យបានគ្រប់ជ្រុងជ្រោយលើស្ថានភាពបច្ចុប្បន្ននៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយលើកអនុសាសន៍អំពីចំណុចខ្វះខាត និងវិធានការកែលំអ ឬបំពេញបន្ថែម ទាំងខាងផ្នែកបង្ការ ការពារ និងទាំងផ្នែកព្យាបាលថែទាំ